ភ្នំពេញ ថ្ងៃទី ៩ កញ្ញា ឆ្នាំ ១៩៩៣

**សារាចរលេខ : ០៣.៩៣ កធស**

**ស្តីអំពីទីអគោចរ « ទីដែលមិនគួរទៅ » និងការឃោសនា**

**អែអង្គាសបច្ច័យនៅតាមទីកន្លែងសាធារណៈ**

ក្រសួងធម្មការ និង កិច្ចការសាសនា

- ដោយអនុលោមតាមស្មារតីនៃសេចក្តីព្រមព្រៀង របស់អនុសំវច្ចរមហាសន្និបាតមន្ត្រីសង្ឃលើកទី ១ ដែលបាន ប្រព្រឹត្តទៅកាលពីថ្ងៃទី ១៥ មិនា ឆ្នាំ ១៩៩២ និង អនុសំវច្ចរមហាសន្និបាតមន្ត្រីសង្ឃលើកទី ២ កាលពីថ្ងៃទី ៦ មិនា ឆ្នាំ ១៩៩៣

- ដោយបានសង្កេតឃើញថា មានបព្វជិតខ្លះបាននិមន្តទៅកាន់ទី ដែលជាអគោចរដ្ឋានពុំគួរគប្បី និង ត្រាច់ចរទៅមក និង ម្យ៉ាងទៀតមានព្រះសង្ឃខ្លះ អាចារ្យវត្តខ្លះ និងពុទ្ធបរិស័ទខ្លះ បាននាំគ្នាដង្ហែក្បួនធ្វើការ ឃោសនាដោយប្រើឧបករណ៍ឧឡោសនសព្ទ រៃអង្គាសបច្ច័យនៅតាមដងផ្លូវនៅក្នុងរដ្ឋធានី ទីក្រុង និង ទីប្រជុំជន ធ្វើអោយប៉ះពាល់ដល់ពុទ្ធបញ្ញត្តិ និង ពុទ្ធានុញ្ញាត ព្រមទាំងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណសង្គម និង ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ របស់ព្រះពុទ្ធសាសនា

- ដើម្បីបង្កើនជំនឿ សេចក្តីទុកចិត្ត និង សេចក្តីគោរពជ្រះថ្លារបស់ប្រជារាស្ត្រចំពោះពុទ្ធសាសនា និង លើកតម្កើង កិត្តិយសព្រះពុទ្ធសាសនា អោយសមឋានៈជាសាសនារបស់រដ្ឋ

រដ្ឋមន្ត្រីក្រសួងធម្មការ និង កិច្ចការសាសនា

សូមពានពុទ្ធដីកាព្រះមេគណគ្រប់ខេត្ត - ក្រុង ព្រះអនុគណគ្រប់ស្រុក - ខ័ណ្ឌ និង ព្រះចៅអធិការគ្រប់វត្ត និង ជំរាបមក លោកនាយកមន្ទីរធម្មការ និង កិច្ចការសាសនាគ្រប់ខេត្ត - ក្រុង សូមព្រះមេត្តាជួយ និង ជួយ ÷

១ - ណែនាំភិក្ខុសាមណេរ នៅក្រោមឱវាទ កុំអោយនិមន្តទៅបិណ្ឌបាត ឬត្រាច់ចរទៅមកកាន់ទីដែលបព្វជិតមិនគប្បី និមន្តទៅ មានអគោចរដ្ឋាន ៦ យ៉ាងជាអាទិ៍គឺ លំនៅដ្ឋានរបស់ស្រីពេស្យាជាកន្លែងមិនគួរត្រាច់ចរទៅ ផ្ទះលក់សុរា ជាកន្លែងមិន គួរនឹងត្រាច់ចរទៅ ព្រមទាំងទីកន្លែងផ្សេងៗទៀត ដូចជា :

- ទីប្រជុំជនដែលមានមនុស្សប្រុស ស្រី ទៅមកឈូឆរ ពពាក់ពពូន ណែនណាន់តាន់តាប់ដូចយ៉ាងទីផ្សារ រានលក់គ្រឿង បរិភោគ-ឧបភោគ, រានលក់សាច់ - ត្រី - បន្លែបង្ការ

- ហាងលក់ទំនិញផ្សេងៗ

- សណ្ឋាគារ - ភោជនីយដ្ឋាន

- តាមក្រសួង - មន្ទីររបស់រដ្ឋ ...ល-

ព្រោះការនិមន្តត្រាច់ចរទៅកាន់កន្លែងទាំងប៉ុន្មានខាងលើនេះ នាំអោយពុទ្ធបរិស័ទ អ្នកមានសេចក្ដីជ្រះថ្លាគោរព ចំពោះ ព្រះពុទ្ធសាសនា កើតមន្ទិលសង្ស័យ រង្កៀសចិត្ត ឬ នាំអោយអ្នកដែលមិនទាន់មានសេចក្ដីជ្រះថ្លា រិះគន់តិះដៀលបាន ។ ហេតុនេះ ទីកន្លែងខាងលើនេះ មិនអនុញ្ញាតអោយបព្វជិត ត្រាច់ចរទៅកាន់ឡើយ ។ វៀរលែងតែមានការចាំបាច់ដែលឃើញថា ជាការខានមិនបានឬដោយមានការអារាធនានិមន្តទើបអាចនិមន្តទៅបានមួយផងប៉ុយកាល ។

២ - ណែនាំភិក្ខុសាមណេរ ដែលនិមន្តចេញពីទីអាវាសវត្តត្រូវអោយ :

ក - យកជាប់ជាមួយនូវឆាយា ឬ សង្ឃដីកាជានិច្ច

ខ - ឃ្លុំចីពរអោយបានរៀបរយ មានបរិមណ្ឌលសមរម្យជាអ្នកបួស ចៀសវាងការពាក់ខ្លាយ ឬ ឃ្លុំសំពីងសំពោង និង ការប្រើវ៉ែនតាពណ៌ខ្មៅ ដែលមិនជាការចាំបាច់ ។

៣ - ណែនាំភិក្ខុសាមណេរ កុំអោយប្រើប្រាស់ឧបករណ៍ ឬ សំភារៈ ដែលមិនចាំបាច់សំរាប់ព្រះសង្ឃដូចជា : ម៉ាស៊ីនថតរូប , ម៉ាស៊ីនថតវីដេអូ , វិទ្យុ , ម៉ាស៊ីនថតសំលេង , យួរកាតាបជាដើម ។

៤ - ណែនាំ និង ហាមប្រាមដាច់ខាតចំពោះភិក្ខុសាមណេរ - អាចារ្យវត្ត កុំអោយធ្វើការរៃអង្គាស ត្រល់រូបភាព ដោយបស្ទាក់ចរាចរតាមផ្លូវសាធារណៈ ឬ ដោយយកព្រះពុទ្ធបដិមាចងក្រៀកដាក់លើរទេះ អូសហែ ជាក្រុម ឬ ក្បួន បានឧត្យាសនសំព្ទ ភ្លេងប៉ាទីងមោង គគ្រឹកគគ្រេងនៅតាមទីក្រុង - ទីប្រជុំជន និងតាមផ្លូវ សាធារណៈ តទៅទៀត ។

ទទួលបានសារាចរនេះ សូមព្រះតេជគុណមេគណ - អនុគណ - ចៅអធិការ លោកអាចារ្យវត្ត និង លោកនាយក មន្ទីរ ធម្មការ ខេត្ត - ក្រុង ផ្សព្វផ្សាយ និង ណែនាំអោយអនុវត្តតាមភារកិច្ចរបស់ព្រះតេជគុណគ្រប់ព្រះអង្គ និង របស់ លោកនាយកមន្ទីរធម្មការខេត្ត - ក្រុង រៀងៗខ្លួន ។

សារាចរនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងធម្មការ និង កិច្ចការសាសនា**

ហត្ថលេខា និង ត្រា

**ឈឹម សៀកឡេង**

បានឃើញ និង យល់ព្រម

វត្តឧណ្ណាលោម ,ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៩៣

សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ
គណៈមហានិកាយ នៃកម្ពុជា

ព្រះហស្ថលេខា និង ត្រា

**ទេព វង្ស**

* * * *